# មេរៀនទី ២៥: រស់នៅដោយព្រះវិញ្ញាណបរិសុទ្ធរបស់ព្រះ

## រ៉ូម ៨:៩-១៧

**គោលបំណង៖** ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយយើងទាំងអស់គ្នា។

**ខគម្ពីរចងចាំរ៉ូម៨:១៤**“*អស់អ្នកណាដែលព្រះវិញ្ញាណនៃព្រះទ្រង់នាំ អ្នកទាំងនោះហើយជាពួកកូនរបស់ព្រះ។*”

**ការថ្វាយបង្គំសំរាប់គ្រូ៖(សូមអានហើយអធិស្ឋានមុនពេលចាប់ផ្តើមបង្រៀន)**
សូមអធិស្ឋានថ្ងៃនេះ៖ «ព្រះជាម្ចាស់ទ្រង់បានធ្វើការដែលលើសពីការអត់ទោសឱ្យទូលបង្គំទៅទៀត។ ព្រះអង្គបានទទួលយកទូលបង្គំ។ ទូលបង្គំស្ទើរតែមិនជឿថាទ្រង់បានរាប់ទូលបង្គំជាកូនរបស់ទ្រង់នោះឡើយ។ សូមជួយទូលបង្គំឱ្យជឿថានេះជាការពិត ហើយឲ្យទូលបង្គំបានព្យាយាមឱ្យអស់ពីសមត្ថភាព ដើម្បីរស់នៅជាមនុស្សថ្មី។ សូមពង្រឹងទូលបង្គំតាមរយៈព្រះចេស្តានៃព្រះវិញ្ញាណបរិសុទ្ធថ្ងៃនេះ»។ នៅពេលអ្នករៀបចំបង្រៀនក្មេងៗសូមចាំថាអ្នកមិននៅម្នាក់ឯងទេ ព្រះវិញ្ញាណបរិសុទ្ធគង់នៅជាមួយអ្នក។

**ចំរៀង៖** ១. ពេលដែលព្រះវិញ្ញាណបរិសុទ្ធ ២. ខ្ញុំច្រៀងថ្វាយព្រះ ៣. ខ្ញុំថ្វាយបង្គំ

### ១. អធិស្ឋាន *(សូមនាំកុមារអធិស្ឋានបើក)*

### ២. ចំរៀង *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

### ៣. ល្បែងកំសាន្ត «អំបិល និងស្ករ»

**សម្ភារៈដែលត្រូវការ៖** កែវ២ ទឹក អំបិល និងស្ករ




១. ចាក់ទឹកចូលក្នុងកែវ២នោះ។ ដាក់អំបិលក្នុងកែវមួយ ហើយនៅក្នុងកែវមួយទៀតដាក់ស្ករ។
២. សួរកុមារថា តើពួកគេឃើញអ្វីប្លែកអំពីទឹកទាំង២កែវនេះ។
៣. សុំឱ្យកុមារ ២នាក់ មកភ្លក់ទឹក និងឲ្យកុមារប្រាប់ពីរសជាតិទឹកដែលពួកគេបានភ្លក់រួច។
៤. ក្មេងដែលផឹកទឹកប្រៃនឹងនិយាយថា ទឹកនេះមិនមានរសជាតិឆ្ងាញ់ទេ។ កុមារដែលផឹកទឹកស្ករនឹងនិយាយថា វាមានរសជាតិផ្អែម។
៥.សូមពន្យល់ដល់កុមារថា នៅពេលដែលព្រះវិញ្ញាណរបស់ព្រះគង់នៅក្នុងយើង មើលពីខាងក្រៅយើងប្រហែលជាមើលទៅមិនខុសពីអ្នកដទៃនោះទេ ប៉ុន្តែនៅខាងក្នុងវិញវាពិតជាមានមានភាពខុសគ្នាយ៉ាងធំ។ ពេលយើងទុកចិត្តលើព្រះយេស៊ូវ នោះព្រះវិញ្ញាណរបស់ព្រះធ្វើឲ្យជីវិតយើងផ្អែម!

### ៤. ការណែនាំមេរៀន

តើប្អូនអាចប្រាប់អ្នកគ្រូ/លោកគ្រូបានទេថានៅក្នុងខ្លួនរបស់ប្អូនមានអ្វីខ្លះ? (សូមឱ្យកុមារឆ្លើយ៖ បេះដូង សួត ឈាម សាច់ដុំ។ល។) តើប្អូនដឹងទេថាសំរាប់អ្នកជឿដល់ព្រះយេស៊ូវមានអ្វីម្យ៉ាង ដែលនៅក្នុងខ្លួនពួកគេដែល

អាចជួយ ពួកគេឲ្យក្លាយទៅជាគ្រិស្តបរិស័ទដ៏ល្អបាន តើប្អូនៗអាចទាយបានទេថាវាជាអ្វី? (ឲ្យកុមារឆ្លើយ)។ បាទ/ចាស នោះគឺជាព្រះវិញ្ញាណបរិសុទ្ធ។ បើទោះបីជាអ្នកមើលមិនឃើញ ដូចជាស្ករ ឬអំបិលក្នុងទឹកក៏ដោយ តែព្រះវិញ្ញាណរបស់ព្រះគង់នៅក្នុងយើងម្នាក់ៗ។ សូមឲ្យយើងបានគិតថា វាគឺជា រឿងដ៏អស្ចារ្យណាស់-ព្រះអង្គដែលធំជាងលោកីយ៍ទាំងមូលបែរជាមកយកចិត្តទុកដាក់ចំពោះមនុស្សតូចៗ ដូចជាប្អូនៗហើយនឹងខ្ញុំដែរនោះ! មិនត្រឹមតែព្រះអង្គទ្រង់យកចិត្តទុកដាក់ប៉ុណ្ណោះទេ ប៉ុន្តែទ្រង់បានយាងមកគង់នៅក្នុងយើងថែមទៀតផង!

## ៥. រឿងនៅក្នុងព្រះគម្ពីរ

នៅក្នុងព្រះគម្ពីរប៉ុលជាសាវកដ៏ស្មោះត្រង់ម្នាក់ ដែលបានសរសេរកណ្ឌគម្ពីរសញ្ញាថ្មីចំនួន ១៣ ក្នុង ចំណោម ២៧ កណ្ឌក្នុងព្រះគម្ពីរ។ ថ្ងៃមួយគាត់បានគិតថា ហេតុអ្វីបានជាគាត់តែងតែជ្រើសរើសនូវជម្រើសដែលខុស នៅពេលដែលគាត់ពិតជាចង់ជ្រើសរើសនូវអ្វីដែលត្រឹមត្រូវអ៊ីចឹង។ បន្ទាប់មកគាត់បានដឹងថា បើគ្រីស្ទបរិស័ទព្យាយាមធ្វើល្អដោយខ្លួនគេនោះពួកគេនឹងបរាជ័យជានិច្ច។ ពួកគេនឹងឃើញថាខ្លួនឯងជាមនុស្សគ្មានមេត្តា ឈ្លើយ ច្រណែន អត្មានិយម លោភលន់ និងអ្វីៗជាច្រើនទៀត។

នៅក្នុងព្រះគម្ពីរ **រ៉ូម ៨** ប៉ុលពន្យល់យើងពីរបៀបដែលព្រះជួយគ្រីស្ទបរិស័ទឱ្យធ្វើការជ្រើសរើសនូវជម្រើសដ៏ល្អមួយ។ ប៉ុលបង្រៀនថាពេលយើងជឿលើព្រះយេស៊ូវ ទ្រង់ប្រទានអំណោយនៃព្រះវិញ្ញាណដល់យើង។ ព្រះគម្ពីរចែងថា ព្រះវិញ្ញាណបរិសុទ្ធជាអ្នកជំនួយ អ្នកសម្រាលទុក្ខ និងជាគ្រូ។ ព្រះវិញ្ញាណបរិសុទ្ធគឺជាដៃគូដ៏ខ្ជាប់ខ្ជួនរបស់យើងដែលផ្តល់ឱ្យយើងនូវក្តីសង្ឃឹម និងកម្លាំង។

ពេលយើងរស់នៅដោយព្រះវិញ្ញាណរបស់ព្រះ នោះយើងអាចងាកចេញពីអំពើបាប ហើយត្រូវបានសម្អាតពីអំពើបាបតាមរយៈការសុគតរបស់ព្រះយេស៊ូនៅលើឈើឆ្កាង។ លើសពីនេះ យើងក៏ត្រូវបានជ្រើសរើសជាកូនរបស់ព្រះផងដែរ! នៅក្នុងព្រះគម្ពីរកូនចិញ្ចឹមមិនអន់ជាងកូនបង្កើតនោះទេ ពួកគេស្មើគ្នា។

ប៉ុលរីករាយដែលព្រះបានទទួលគាត់ជាកូន តាមរយៈជំនឿរបស់គាត់លើព្រះយេស៊ូវ។ ប៉ុលក៏បានដឹងដែរថា តាមរយៈព្រះវិញ្ញាណបរិសុទ្ធដែលគង់នៅក្នុងគាត់ គាត់អាចយកឈ្នះការល្បួងនៃអំពើបាប។ យើងអាចធ្វើបានដូចគាត់អ៊ីចឹងដែរ។ យើងគ្មានអំណាចធ្វើជាក្មេងប្រុសស្រីល្អទេ។ ប៉ុន្តែយើងមានព្រះវិញ្ញាណបរិសុទ្ធ ដែលតែងតែជួយយើងឲ្យធ្វើការជ្រើសរើសល្អ ហើយធ្វើជាគ្រីស្ទបរិស័ទដ៏ល្អបាន។

សូមគិតតាបបែបដូច្នេះ ព្រះជាអ្នកបង្កើតសកលលោកទាំងមូល ជាព្រះដែលមានបន្ទូលឲ្យកើតពិភពលោកមក ហើយជាព្រះដែលគង់នៅក្នុងយើង! ពិតជាអស្ចារ្យណាស់! អ្វីដែលយើងត្រូវធ្វើគឺជឿ ហើយទុកចិត្តទ្រង់។ ក្នុងនាមជាកូនរបស់ព្រះ យើងអាចធានាបានថា ព្រះវិញ្ញាណរបស់ព្រះគង់នៅក្នុងយើង។

## ៦. សំនួរពិភាក្សា

១. តើនរណាមករស់នៅក្នុងយើងពេលយើងជឿលើព្រះ? *ព្រះវិញ្ញាណបរិសុទ្ធ*

២. តើព្រះវិញ្ញាណបរិសុទ្ធធ្វើអ្វីពេលទ្រង់មកគង់នៅក្នុងយើង ? *ព្រះវិញ្ញាណបរិសុទ្ធជួយយើងឲ្យមានចិត្តដូចព្រះ ហើយប្រទានឲ្យយើងនូវអំណាចដើម្បីប្រឆាំងនឹងការល្បួងនៃអំពើបាប*

៣. តើនរណាខ្លះអាចទទួលបានព្រះវិញ្ញាណបរិសុទ្ធ? *អស់អ្នកណាដែលជឿលើព្រះ ជាព្រះដែល បានចាត់ព្រះរាជបុត្រាទ្រង់ គឺព្រះយេស៊ូវឲ្យសុគតជំនួសអំពើបាបរបស់យើង ហើយមានព្រះជន្មរស់ឡើងវិញ ដើម្បីឲ្យយើងមានជីវិតអស់កល្បនៅស្ថានសួគ៌*

**៧. ខគម្ពីរចងចាំ** រ៉ូម ៨:១៤

**៨. ហត្ថកម្ម** «សត្វព្រាប»



**សម្ភារៈដែលត្រូវការ៖** ចានក្រដាស កន្ត្រៃ កាវ ប៊ិក

១. ឱ្យចានក្រដាសទៅកុមារម្នាក់មួយ ហើយឱ្យពួកគេគូររូបសត្វព្រាបនៅលើចាននៅចំកណ្តាល។

២. កាត់សងខាងធ្វើជាស្លាប ហើយកាត់តួខ្លួនព្រាបចេញ។

៣. យកការបិទចុងទាំងសងខាងជាមួយគ្នាដើម្បីធ្វើជាស្លាប

៤. គូរភ្នែកលើក្បាលរបស់សត្វព្រាប។ យកការបិទតួខ្លួនសត្វព្រាបនៅចំកណ្តាលស្លាប។

៥. នៅពេលណាដែលប្អូនឃើញសត្វព្រាបនេះ សូមចាំថាព្រះវិញ្ញាណបរិសុទ្ធគង់ជាមួយប្អូនជានិច្ច!

**៩. ចំរៀង** *(រើសចំរៀងខាងលើ១បទហើយច្រៀងជាមួយសិស្ស)*

**១០. អធិស្ឋាន** *(សូមនាំកុមារអធិស្ឋានបិទ)*